**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ២០១/២៤ ក.ប/ខ.ល

# សារលិខិតអបអរសាទរ

## សូមគោរពជូន

## ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី២ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

*ជាទីគោរពដ៏ខ្ពង់ខ្ពស់!*

នាឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយទឹកចិត្តសោមនស្សរីករាយ តាងនាមថ្នាក់ដឹកនាំ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា សូមសម្តែងនូវមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅចូលរួមអបអរសាទរដោយស្មោះអស់ពីដួងចិត្តជូនចំពោះ **ឯកឧត្តម អ៊ុច បូររិទ្ធ** ដែលត្រូវបានជ្រើសរើសជា **អនុប្រធានទី២ ព្រឹទ្ធសភា** នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការបោះឆ្នោតនៃសម័យប្រជុំដំបូង នីតិកាលទី៥ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នាថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤។

ការទទួលបាននូវការជ្រើសតាំងនេះ គឺជាកិត្តិយសដ៏ធំធេងសម្រាប់ប្រទេសជាតិ និងប្រជាជនខ្មែរគ្រប់រូប និងស័ក្តិសមបំផុតសម្រាប់ **ឯកឧត្តម** ដែលបានបូជានូវកម្លាំងកាយ កម្លាំងប្រាជ្ញាស្មារតី និងធ្វើពលិកម្មសព្វបែបយ៉ាងដើម្បីបុព្វហេតុជាតិមាតុភូមិ ដើម្បីបន្តចូលរួមដឹកនាំប្រទេសកម្ពុជាឱ្យសម្រេចបានជោគជ័យ ការពារបូរណភាពទឹកដី អធិបតេយ្យភាព សុខសន្តិភាព សាមគ្គីភាព ស្ថិរភាពសង្គម និងជំរុញការអភិវឌ្ឍជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យបន្ថែមទៀត។

យើងខ្ញុំមានជំនឿជឿជាក់ថា ជាមួយនឹងសមត្ថភាព បទពិសោធន៍ការងារដ៏ខ្ពង់ខ្ពស់ និងភាពចាស់ទុំខាងនយោបាយផងនោះ **ឯកឧត្តម** នឹងរួមចំណែកដឹកនាំព្រឹទ្ធសភាឱ្យទទួលបានជោគជ័យ រីកចម្រើន រឹងមាំថែមទៀត លើការពង្រឹងស្ថាប័ននីតិប្បញ្ញត្តិ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា ឱ្យបោះជំហានទៅមុខកាន់តែរឹងមាំ ក្រោមម្លប់ព្រះបារមីនៃអង្គ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាព្រះប្រមុខរដ្ឋ**។

ឆ្លៀតក្នុងឱកាសដ៏មហាប្រសើរថ្លៃថ្លាឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នា សូមលើកហត្ថប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយថែរក្សា អភិបាលប្រោះព្រំសព្វសាធុការពរជ័យគ្រប់ប្រការជូន **ឯកឧត្តម** និង **លោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមសមប្រកបដោយព្រះពុទ្ធពរដ៏ប្រសើរថ្លៃថ្លាទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី២ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវភក្តីភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

ថ្ងៃពុធ ១០រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩